# មហាកាល និងនន្ទិកេស្វរ

ចាប់ពីរវាងស.វ.ទី១០មក សំណង់ប្រាសាទដែលឧទ្ទិសដល់ព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាមួយចំនួននៅក្នុងសិល្បៈខ្មែរសម័យបុរាណ គេតែងឃើញមានបដិមាទ្វារបាលនៅឈរយាមខាងមុខច្រកចូល។ ជាទូទៅ នៅក្នុងទេវកថាព្រហ្មញ្ញសាសនា ទ្វារបាលទាំងនោះមានឈ្មោះខុសៗគ្នាទៅតាមទិសប្រភេទសំណង់ដែលគេសាងឡើង។ នៅក្នុងអត្ថបទខ្លីនេះ យើងនឹងបង្ហាញអំពីតួអង្គទ្វារបាលរបស់សំណង់ព្រះឥសូរចំនួនពីរនាក់គឺ មហាកាល និងនន្ទិកេស្វរ។

នៅក្នុងព្រហ្មញ្ញសាសនា មហាកាល និងនន្ទិកេស្វរ គេច្រើនស្គាល់ក្នុងឈុតមួយនៃទេវកថាព្រហ្មញ្ញសាសនាបង្ហាញអំពី "ក្រុងរាពណ៍រញ្ជួញភ្នំកៃលាស" (រាវណានុគ្រហមុត៌ិ)។ សាច់រឿងនេះរៀបរាប់នៅក្នុងគម្ពីររាមយណ ក្បាលទី៧ ឧត្តរកន្ត ជំពូកទី១ ដែលរៀបរាប់ថា៖ "ក្រុងរាពណ៍ដែលជាស្តេចនៃក្រុងលង្កា បានធ្វើដំណើរទៅកាន់ភ្នំកៃលាសដែលជាលំនៅដ្ឋានរបស់ព្រះឥសូរ និងព្រះនាងឧមា។ ទៅដល់ទីនោះ ក្រុងរាពណ៍ក៏បានជួបនឹងអ្នកយាមទ្វារ គឺមហាកាល និងនន្ទិកេស្វរ។ អ្នកយាមទាំងពីរដែលត្រូវជាជំនួយការរបស់ព្រះឥសូរផងនោះ មិនអនុញ្ញាតឱ្យក្រុងរាពណ៍ចូលទៅក្នុងឡើយ នាំឱ្យក្រុងរាពណ៍មានកំហឹងយ៉ាងខ្លាំងរហូតដល់ចាប់លើកភ្នំកៃលាសរញ្ជួយអស់ស្ថានទាំងបី។ ព្រះឥសូរ ក៏យកម្រាមជើងដាក់នៅលើភ្នំដើម្បីបង្កើនទម្ងន់ភ្នំសង្កត់ក្រុងរាពណ៍ឱ្យជាប់នៅក្នុងភ្នំ។ ព្រះឥសូរក៏បានបញ្ជាឱ្យក្រុងរាពណ៍ស្រែកច្រៀងពោលសរសើរទ្រង់រហូតដល់ ១០០០ឆ្នាំទើបព្រមលែងក្រុងរាពណ៍ចេញពីភ្នំសង្កត់នោះ"។

តាមសាច់រឿងនេះ មានន័យថា មហាកាល និងនន្ទិកេស្វរ គឺជាអ្នកយាមទ្វារនៅភ្នំកៃលាសដែលជាស្ថានរបស់ព្រះឥសូរ ហើយអ្នកទាំងពីរក៏ជាជំនួយការរបស់ទ្រង់ដែរ។ ជាទូទៅ គេដឹងថា មហាកាល និងនន្ទិកេស្វរ គឺជាអ្នកយាមនៅច្រកទ្វារខាងកើត។ ចំណែកឯខាងលិចវិញ មានអ្នកយាមឈ្មោះ វ្ឫសភ និងស្កន្ទ, ខាងជើងឈ្មោះ ទេវី និងចណ្ឌេស្វរ និងខាងត្បូងឈ្មោះ ភ្ឫង្គ និងវិនាយក។ រីឯនៅស្ថានព្រះវិស្ណុវិញ គេស្គាល់ឈ្មោះទ្វារបាលចំនួនពីរថា ជយ និងវិជយ។

ដោយឡែក នៅក្នុងសិលាចារឹកប្រាសាទគោកពោធិ ខេត្តសៀមរាប K.256 បង្ហាញភាពចម្លែកបន្តិចថា មហាកាល និងនន្ទិកេស្វរ ដែលគេស្គាល់ថាជាតួអង្គទ្វារបាលនៅច្រកទ្វារខាងកើតរបស់ព្រះឥសូរ បែរជាឈរយាមទ្វារសំណង់ប្រាសាទព្រះវិស្ណុទៅវិញ។ ដូច្នេះ តាមរយៈសិលាចារឹកនេះ នាំឱ្យអ្នកស្រាវជ្រាវ Alexis Sanderson សន្និដ្ឋានថា នៅសម័យអង្គរ ទំនាក់ទំនងរវាងនិកាយសៃវ និងនិកាយបញ្ចរាត្រិកវៃស្នវ គឺមានភាពទាក់ទងគ្នាខ្លាំង។ សិលាចារឹកនោះរៀបរាប់ថា៖

ចក្រោរ ចក្រិសោភក្ត្យាត សំក្រោតបជំ អាស្រមំ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ធាសីធាសហិរណ្យាទិឱនៃ អាបូរយច ច សះ
ទ្វិប្រស្ថញ ចាត្រ សុច្បន្ធំ ធាតរ្យំ ប្រតិវាសរម
ត្រិប្រស្ថនៃវយជ្វញ ច ចក្រិណោ សោ ប្យ អកាល្បយត
នន្ទិនំ ស្រីមហាកាលំ ទ្វាស្ថំ វិស្ណោរ វ្យិជាយ សះ
ទ្វិប្រស្ថម អន្វហាន តាភ្យាំ យជ្វន ទេយម អកាល្បយត។

*ប្រែថា៖* ***ក្រៅពីគោរពដល់អស្ចារ្យចំពោះព្រះវិស្ណុ ទ្រង់បានរកឃើញអាស្រមសំក្រាន្តបត និង បានបរិច្ចាកអ្នកបម្រើប្រុសស្រី មាស និងវត្ថុមានតម្លៃផ្សេងៗ។ ទ្រង់បានផ្តល់ជូនគ្រឿងតង្វាយ ចំនួនពីរប្រស្ថជាប្រចាំដល់ទីនេះ និងថ្វាយបីប្រស្ថចំពោះវិស្ណុ។ ទ្រង់បានស្ថាបនារូបនន្ទិន និងមហា កាលឈរយាមទ្វារនៅប្រាសាទព្រះវិស្ណុនេះ ហើយថ្វាយគ្រឿងតង្វាយពីរប្រស្ថចំពោះព្រះ។***

*នៅទីតាំងដែលរកឃើញសិលាចារឹកនេះ (ប្រាសាទគោកពោធិ តួប៉ម ២) គឺពិតជាមានតម្កល់ បដិមាទ្វារបាលចំនួនពីរនៅខាងមុខប្រាសាទដូចការរៀបរាប់របស់សិលាចារឹកដូច្នោះមែន។ បដិមាទាំងពីរនោះ គឺប្រាកដជាទ្វារបាលទិសខាងកើតរបស់ព្រះឥស្វរ ដែលមានឈ្មោះថា មហាកាល និងនន្ទិកេស្វរ។ បដិមាទាំងពីរនោះ មានទឹកមាំ កាចសាហាវ បែរមុខត្រង់ មាឌធំខ្ពស់ឈរនៅលើ ទម្រថ្ម ក្បាលពោះកំប៉ោង នៅលើរាងកាយមានលម្អគ្រឿងអលង្ការផ្សេងៗ ហើយនៅដៃម្ខាងមាន កាន់ដំបងធំមួយ (រូបលេខ១)។ ទ្វារបាលទាំងពីរនេះ ត្រូវជនទុច្ចរិតលួចយកចេញនៅទសវត្សរ៍ ១៩៧០។ ក្នុងនោះ ស្ថានភាពបច្ចុប្បន្នរបស់ទ្វារបាលមួយក្នុងចំណោមទាំងពីរនេះ បានបាត់បង់ ក្បាល និងផ្នែកខ្លះនៃដៃ ហើយកំពុងចរាចរនៅទីផ្សារអន្តរជាតិ (រូបលេខ២-៤)។*

*សរុបជារួមមក តាមរយៈសិលាចារឹក និងបដិមាទ្វារបាលទាំងពីរដែលគេរកឃើញនៅ ប្រាសាទគោកពោធិ គឺជាតឹកតាងដែលបញ្ជាក់ថា ខ្មែរបានស្គាល់ជ្រួតជ្រាបយ៉ាងច្បាស់នូវតួអង្គ ទ្វារបាលនៅក្នុងនិកាយផ្សេងៗនៃសាសនាព្រាហ្មណ៍។ ជាពិសេស គឺតួអង្គមហាកាល និងនន្ទិកេ ស្វរ ដែលបានលើកមកបង្ហាញដោយសង្ខេបខាងលើតែម្តង៕*

*អត្ថបទដោយ៖ ម៉ង់ វ៉ាលី*



រូបលេខ១៖ បដិមាទ្វារបាលមហាកាល និង៍នន្ទិកេស្វរ នៅប្រាសាទគោកពោធិ (រូបភាព៖ EFEO)



រូបលេខ២៖ បដិមាទ្វារបាលមហាកាល ឬ នន្ទិកេស្វរ មកពីប្រាសាទគោកពោធិ ដែលលួចចេញពីកម្ពុជានៅរវាងទសវត្សរ៍ ១៩៧០ និងធ្លាប់ចរាចរលក់នៅទីផ្សារអន្តរជាតិ (រូបភាព៖ Koller Auctions Ltd.)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



*រូបលេខ៣៖ បដិមាទ្វារបាលមហាកាល ឬ នន្ទិកេស្វរ មកពីប្រាសាទគោកពោធិ ដែលលួចចេញពីកម្ពុជានៅរវាងទសវត្សរ៍ ១៩៧០ និងធ្លាប់ចរាចរលក់នៅទីផ្សារអន្តរជាតិ (រូបភាព៖* Koller Auctions Ltd.)

*អត្ថបទដោយ៖ ម៉ង់ វ៉ាលី*



រូបលេខ៤៖ បដិមាទ្វារបាលមហាកាល ឬ នន្ទិកេស្វរ មកពីប្រាសាទគោកពោធិ ដែលលួចចេញពីកម្ពុជានៅរវាងទសវត្សរ៍ ១៩៧០ និងធ្លាប់ចរាចរលក់នៅទីផ្សារអន្តរជាតិ (រូបភាព៖ Koller Auctions Ltd.)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

# ឯកសារយោង

*សរ សុជា, ២០០៤, ចម្លាក់ទ្វារបាលក្នុងសិល្បៈខ្មែរសម័យបុរាណ, ភ្នំពេញ។*

Alexis, S. 2003-2004. ‘The Saiva Religion among the Khmers’, BEFEO, Vol. 90-91, pp.349-462, Paris.

Bhatacharya, K. 1961. *Les Religions Brahmaniques Dans L’Ancien Cambodge, D’aprѐs L’épigraphie et L’Iconographie,* EFEO, Paris.

Roveda, V. 2005. *Image of the gods,* River Book, Bangkok.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION